# ការឆ្លើយតបចំពោះកូវីត ១៩

ចម្លើយចំពោះសំណួរ
ថ្ងៃទី ១៦ ខែមេសា ឆ្នាំ ២០២០

បន្ថែមទៅលើឯកសារ « ការដឹកនាំសម្រាប់ពិធីបរិសុទ្ធ ការប្រសិទ្ធពរ និងដំណើរការក្នុងសាសនាចក្រសំខាន់ៗដទៃទៀត » ឯកសារនេះអាចត្រូវបានប្រើដើម្បីឆ្លើយសំណួរអំពីការគ្រប់គ្រងសាសនាចក្រអំឡុងការរាតត្បាតកូវីត ១៩ ។

ឯកសារទាំងនេះត្រូវបានចេញមកដើម្បីឆ្លើយតបចំពោះការរំខានដល់ការដំណើរការក្នុងសាសនាចក្រ និងសកម្មភាពរបស់សមាជិកដែលបានបណ្តាលមកពីការរាតត្បាតកូវីត ១៩ នៅទូទាំងពិភពលោក ។ វាគួរតែប្រើប្រាស់តាមការណែនាំ តាមរយៈពេលដែលការរាតត្បាតនេះ និងការដាក់កំហិតជាផ្លូវការដែលទាក់ទងនឹងរឿងនេះទៅលើការប្រជុំសាសនាចក្រ និងការបង្ហាញជាសាធារណៈដែលមាននៅក្នុងប្រទេស ឬភូមិសាស្ត្រជាក់លាក់ក្នុងប្រទេសមួយ ។
ការដឹកនាំដទៃទៀតអាចនឹងចេញមកនៅពេលក្រោយ ។

ប៊ីស្សព និងប្រធានស្តេក គួរតែបានបានដឹង និងយកចិត្តទុកដាក់ចំពោះស្ថានភាព និងច្បាប់ក្នុងមូលដ្ឋាន ។ ពួកគេគួរតែលើកទឹកចិត្តសមាជិកឲ្យគោរពតាមច្បាប់ ។ សម្រាប់សំណួរ និងចម្លើយនីមួយៗដែលបានរៀបរាប់ដូចខាងក្រោម សូមធ្វើតាមដោយមានការយកចិត្តទុកដាក់ ៖

- ការនៅឆ្ងាយពីមនុស្សច្រើន ការលាងសម្អាតដៃ និងការអនុវត្តដទៃទៀត ដែលមានពិពណ៌នានៅក្នុង « វង្វាស់នៃការបង្ការសម្រាប់សមាជិក » មាននៅ newsroom.churchofjesuschrist.org/article/coronavirus-update#preventative-measures
- គោលការណ៍ដែលដាក់ខ្លួននៅដាច់ដោយឡែក និងប្រត្រកូលនានាដូចបានណែនាំដោយពេទ្យជំនាញ និងថ្នាក់ដឹកនាំរដ្ឋាភិបាល ។
- បទបញ្ជា ច្បាប់ និងសេចក្តីណែនាំរបស់រដ្ឋាភិបាលដែលបានបង្កើតឡើងនៅក្នុងទីតាំងនីមួយៗ

ឯកសារបន្ថែមទាក់ទងនឹងកូវីត ១៩ គឺមាននៅ newsroom.ChurchofJesusChrist.org.

បើមានសំណួរពិបាកៗជាក់លាក់ ប្រធានស្តេកគួរតែទាក់ទងទៅគណៈប្រធានតំបន់របស់ពួកគេ ។

## I. ពិធីបរិសុទ្ធបព្វជិតភាព និងស្ថានភាពគ្រួសារ

### ការធ្វើពិធីសាក្រាម៉ង់

តើអ្នកកាន់បព្វជិតភាពអាចផ្តល់ការងារបម្រើសាក្រាម៉ង់នៅក្នុងផ្ទះរបស់សមាជិកវួដដទៃទៀតដែលពុំមានសង្ឃ ឬអ្នកកាន់បព្វជិតភាពមិលគីស្សាដែកសក្ដិសមឬទេ ?

*ជាទូទៅ, បាន ។ ថ្មីៗនេះ ការដឹកនាំរបស់រដ្ឋាភិបាល ឬច្បាប់ក្នុងមូលដ្ឋាន បានដាក់កំហិតដល់អានុវត្តនេះនៅក្នុងជាតិសាសន៍ និងទីក្រុងជាច្រើន ។ រហូតដល់មានការជូនដំណឹងបន្ថែម នៅក្នុងកន្លែងទាំងនេះ អ្នកកាន់បព្វជិតភាពពុំគួរចូលក្នុងផ្ទះរបស់សមាជិកសាសនាចក្រណាដែលពួកគេពុំជាប់ទាក់ទងក្នុងការធ្វើពិធីសាក្រាម៉ង់ឡើយ ។ អំឡុងគ្រានេះ សមាជិកអាចត្រូវបានប្រទានពរដោយការសិក្សាការប្រសិទ្ធពរសាក្រាម៉ង់ និងតាំងចិត្តជាថ្មីដើម្បីរស់នៅតាមសេចក្តីសញ្ញាដែលបានធ្វើឡើង និងការអធិស្ឋានសម្រាប់ថ្ងៃដែលពួកគេនឹងទទួលបានដោយផ្ទាល់ ដែលធ្វើឡើងដោយអ្នកកាន់បព្វជិតភាពត្រឹមត្រូវ ។*

### ពរជ័យអយ្យកោ

តើពរជ័យអយ្យកោអាចបន្តដាក់កាលវិភាគណាត់ជួបឬទេ ?

*ពរជ័យអយ្យកោគួរតែពន្យាពេលជាបណ្តោះអាសន្ន ។ ទោះជាយ៉ាងណា, កន្លែងណាដែលអាចធ្វើទៅបាន អស់អ្នកដែលរៀបចំដើម្បីបម្រើបេសកកម្មគួរតែទទួលបានពរជ័យនៃអយ្យកោពីមុនចាប់ផ្តើមការបម្រើផ្សព្វផ្សាយសាសនារបស់ពួកគេ ។*

### អាពាហ៍ពិពាហ៍ ពិធីទទួលភ្ញៀវ និងពិធីបុណ្យសព

តើការណែនាំថ្មីអនុញ្ញាតឲ្យមានអាពាហ៍ពិពាហ៍ (រួមមានពិធីទទួលភ្ញៀវ) និងពិធីបុណ្យសពនៅក្នុងសាលាប្រជុំដែរឬទេ ?

*កន្លែងដែលមានការដាក់កំហិតដោយច្បាប់រដ្ឋាភិបាល នោះអាពាហ៍ពិពាហ៍ ពិធីទទួលភ្ញៀវ និងពិធីបុណ្យសព មិនគួរធ្វើឡើងនៅក្នុងសាលាប្រជុំទេ ។ បើអនុញ្ញាតដោយច្បាប់ នោះប៊ីស្សព និងប្រធានស្តេក អាចធ្វើជាអធិបតីនៅក្នុងអាពាហ៍ពិពាហ៍ដោយរក្សាគម្លាតពីមនុស្សជាសង្គមតាម*

*ត្រឹមត្រូវ ។ បច្ចេកវិទ្យាក៏អាចប្រើប្រាស់ដើម្បីអនុញ្ញាតឲ្យគ្រួសារ និងមិត្តភក្តិមើលកម្មវិធីផងដែរ ។ ថ្នាក់ដឹកនាំ និងសមាជិក គួរតែធ្វើតាមការដាក់បង្គាប់ ច្បាប់ និងការណែនាំរបស់រដ្ឋាភិបាល។*

*នៅពេលអនុញ្ញាតដោយច្បាប់ គណៈប៊ីស្សព និងសមាជិកនៃគណៈប្រធានស្តេក អាចធ្វើជាអធិបតីនៅកម្មវិធីបញ្ចុះ ។ បច្ចេកវិទ្យាក៏អាចត្រូវបានប្រើប្រាស់ដើម្បីអនុញ្ញាតឲ្យគ្រួសារ និងមិត្តភក្តិមើលកម្មវិធី និងថតចម្លងផងដែរ ។ បើចង់បាន កម្មវិធីរំឭកចាំធំមួយអាចធ្វើឡើងនៅពេលក្រោយ តាមស្ថានភាពអនុញ្ញាត ។*

### ការដាក់ឈ្មោះ និងការប្រសិទ្ធពរកុមារ

តើការណែនាំអនុញ្ញាតឲ្យមានការប្រសិទ្ធពរដល់ទារកនៅក្នុងផ្ទះឬទេ ?

*ប្រាកដណាស់ ។ នៅពេលបានការអនុញ្ញាតពីប៊ីស្សព នោះការប្រសិទ្ធពរអាចធ្វើឡើងនៅក្នុងផ្ទះរបស់គ្រួសារនោះ ជំនួសឲ្យនៅក្នុងការប្រជុំនៅព្រះវិហារ ។ វាគួរតែត្រូវបានរាយការណ៍ដោយត្រឹមត្រូវ ។*

## II. ការគ្រប់គ្រងវួដ និងស្តេក

### ការប្រជុំ និងការសម្ភាស

តើការប្រជុំគណៈប៊ីស្សព ការប្រជុំគណៈប្រធានស្តេក ការប្រជុំក្រុមប្រឹក្សាជាន់ខ្ពស់ និងការប្រជុំគណៈប្រធាន និងការសម្ភាសដទៃទៀតអាចធ្វើឡើងដោយផ្ទាល់ឬទេ ?

*ទាំងនេះគឺជាការសម្រេចចិត្តដែលគួរតែធ្វើឡើងតាមមូលដ្ឋានដោយផ្អែកទៅលើព័ត៌មានដែលមាន ។ ការប្រជុំ និងការសម្ភាស អាចធ្វើឡើងតាមបច្ចេកវិទ្យា បើអាចធ្វើទៅបាន ។*

### ការកត់ត្រាការចូលរួមការប្រជុំ

ដោយមានការផ្អាកការប្រជុំ តើរបាយការណ៍ការចូលរួមត្រូវគណនា និងរាយការណ៍ដោយរបៀបណា ?

*ការចូលរួមនឹងពុំរាយការណ៍ទេ ដោយសារកម្មវិធីថ្ងៃអាទិត្យ មានការផ្អាកជាបណ្តោះអាសន្ន ។*

## ការប្រើប្រាស់អគារ និងទីកន្លែង

តើអគារ និងកន្លែងកីឡា អាចនៅតែប្រើប្រាស់ឬទេ ? តើយុវវ័យអាចជួបជុំគ្នាដើម្បីលេងបាល់ទាត់នៅក្រៅសាលាប្រជុំក្នុងទីវាលបានឬទេ ?

*សកម្មភាពសាខា វួដ និងស្តេក គឺត្រូវផ្អាកជាបណ្តោះអាសន្ន ។ បុគ្គលម្នាក់ៗគួរតែធ្វើតាម « រង្វាស់ការបង្ការសម្រាប់សមាជិក » ។ សមាជិក គួរតែធ្វើតាមការដាក់បង្គាប់ ច្បាប់ និងការណែនាំរបស់រដ្ឋាភិបាល ។*

តើសកម្មភាពប្រចាំថ្ងៃដទៃទៀត ដូចជាគីឡា និងការហាត់សមរបស់ក្រុមចម្រៀង និងមេរៀនព្យាណូ នៅក្នុងសាលាប្រជុំអាចបន្តមានឬទេ ?

*សកម្មភាពនានាដូចជា កីឡា ការហាត់សមរបស់ក្រុមចម្រៀង និងមេរៀនព្យាណូ ត្រូវបានផ្អាកជាបណ្តោះអាសន្ន ។ សមាជិក គួរតែធ្វើតាមការដាក់បង្គាប់ ច្បាប់ និងការណែនាំរបស់រដ្ឋាភិបាល ។*

តើគួរតែធ្វើជាយ៉ាងណាជាមួយនឹងថ្នាក់ការជាសះស្បើយពីការញៀន និងថ្នាក់ខ្លួនទីពឹងខ្លួនដែលធ្វើឡើងប្រចាំសប្តាហ៍នៅក្នុងអគារសាសនាចក្រ ?

*វាគួរតែធ្វើឡើងតាមបច្ចេកវិទ្យា ។*

តើមជ្ឈមណ្ឌលពង្សប្រវត្តិនៅក្នុងមជ្ឈមណ្ឌលស្តេកគួរតែបិទឬទេ ?

*ប្រាកដណាស់ ។ អ្នកទទួលគួរតែប្រើបច្ចេកវិទ្យាមកពីផ្ទះ ។*

## ថ្នាក់សិក្ខាសាលា និង ថ្នាក់វិទ្យាស្ថាន

*សម្រាប់សំណួរទាំងអស់ សូមមើលសេចក្តីណែនាំស៊ីអ៊ីអែសក្នុងការឆ្លើយតបចំពោះកូវីត ១៩ ។*

## ដង្វាយមួយភាគក្នុងដប់ និងដង្វាយតមអាហារ

តើគណៈប៊ីស្សព នឹងទទួលដង្វាយមួយភាគដប់ និងដង្វាយនានាដោយផ្ទាល់ ហើយវាយបញ្ចូលប្រតិបត្តិការអំឡុងសប្តាហ៍ ឬគួរតែវាធ្វើឡើងតែតាមអេឡិចត្រូនិច អំឡុងការផ្អាកការប្រជុំនេះ ?

*នៅពេលណាដែលអាចធ្វើទៅបាន សមាជិកគួរតែធ្វើការបរិច្ចាគរបស់ពួកគេតាមអ៊ិនធើរណិត ។ សមាជិកដែលពុំអាចចូលទៅធ្វើការបរិច្ចាគតាមអ៊ិនធើរណិត អាចនៅតែផ្តល់ដង្វាយដោយផ្ទាល់ទៅកាន់សមាជិកណាម្នាក់នៃគណៈប៊ីស្សព ឬផ្ញើសំបុត្រដង្វាយដោយប្រើស្រោមសំបុត្រដែលមានដាក់អាសយដ្ឋានជាស្រេច លើកលែងតែគណៈប្រធានតំបន់មើលឃើញថាការអនុវត្តនេះវាពុំសមរម្យ ។ សំណួរបន្ថែមគួរតែសួរទៅកាន់គណៈប្រធានតំបន់ ។*

## សន្និសីទដ.ក.យ

តើសន្និសីទដ.ក.យរបស់យុវវ័យធ្វើឡើងនៅរដូវក្តៅ (ឆ្នាំ ២០២០ ) នេះឬទេ ?

*សន្និសីទដ.ក.យ ឆ្នាំ ២០២០ បានដាក់កាលវិភាគដើម្បីធ្វើឡើងនៅក្នុងសហរដ្ឋ និងកាណាដា ក្នុងឆ្នាំ ២០២០ ត្រូវបានផ្អាករហូតដល់ឆ្នាំ ២០២១ ។ ស្តេកទាំងឡាយបានអញ្ជើញឲ្យចូលរួមនៅក្នុងសន្និសីទដ.ក.យ ក្នុងឆ្នាំ ២០២០ ឥឡូវនឹងចូលរួមនៅក្នុងឆ្នាំ ២០២១ ។ កាលវិភាគ សន្និសីទដ.ក.យ ដែលបានធ្វើបច្ចុប្បន្នភាព ធ្វើឡើងនៅក្នុងសហរដ្ឋអាមេរិក និងកាណាដា ក្នុងឆ្នាំ ២០២១-២៣ នឹងធ្វើបច្ចុប្បន្នភាពក្នុងពេលឆាប់ៗ ។ ការប្រគល់ប្រាក់វិញ នឹងធ្វើឡើងដោយស្វ័យប្រវត្តិទៅកាន់អស់អ្នកដែលបានចុះឈ្មោះ ។ យុវវ័យមកពីស្តេក បានអញ្ជើញនៅក្នុងឆ្នាំ ២០២០ ដែលនៅតែមានអាយុត្រូវតាមលក្ខខណ្ឌនឹងត្រូវបានអញ្ជើញឲ្យចូលរួមក្នុងសន្និសីទដ.ក.យ ក្នុងឆ្នាំ ២០២១ ។ នៅក្រៅសហរដ្ឋ និងកាណាដា នោះគណៈប្រធានតំបន់នឹងផ្តល់ការណែនាំថាតើសន្និសីទដ.ក.យនឹងធ្វើឡើងឬអត់ ស្របតាមការណែនាំអំពីកូវីត ១៩ ដែលបានបង្កើតឡើងដោយរដ្ឋាភិបាលនៅក្នុងសហគមន៍ និងប្រទេសរបស់ពួកគេ ។ ព័ត៌មានបន្ថែមអំពីសន្និសីទដ.ក.យ មាននៅក្នុង FSY.ChurchofJesusChrist.org ។*

# III. ការបម្រើជាអ្នកផ្សព្វផ្សាយសាសនា

## ពីមុនបេសកកម្ម

តើបេក្ខជនផ្សព្វផ្សាយសាសនាគួរតែបន្តដំណើរការតាមរយៈថ្នាក់ដឹកនាំបព្វជិតភាពក្នុងមូលដ្ឋានឬទេ ? តើអ្នកផ្សព្វផ្សាយសាសនានឹងបន្តហៅនៅរយៈពេលខ្លីខាងមុខនេះឬទេ ?

*ប្រាកដណាស់ ។*

តើប៊ីស្សព និងប្រធានស្តេកអាចសម្ភាសអ្នកត្រៀមជាអ្នកផ្សព្វផ្សាយសាសនាដោយផ្ទាល់ឬទេ ?

*បាទ ប៉ុន្តែការសម្ភាសអ្នកត្រៀមជាអ្នកផ្សព្វផ្សាយសាសនា គួរតែធ្វើឡើងពីចម្ងាយដោយការប្រើបច្ចេកវិទ្យាមើលមុខគ្នាឃើញ តាមដែលអាចធ្វើទៅបាន ។*

## ជីវិតអ្នកផ្សព្វផ្សាយសាសនា

តើអ្នកផ្សព្វផ្សាយសាសនាអាចបន្តបង្រៀនអ្នករៀនរបស់ពួកគេ *ដោយផ្ទាល់* នៅពេលពួកគេតម្រូវឲ្យស្ថិតនៅក្នុងផ្ទះរបស់ពួកគេឬទេ ?

*ទេ ។ អ្នកផ្សព្វផ្សាយសាសនាគួរតែអនុវត្តតាមបង្គាប់ ច្បាប់ និងការណែនាំរបស់រដ្ឋាភិបាល ក៏ដូចជាការដឹកនាំមកពីគណៈប្រធានតំបន់ និងប្រធានបេសកកម្ម ។ ទោះជាយ៉ាងណា ពួកគេអាចនៅតែបង្រៀនដល់អ្នករៀនរបស់ពួកគេតាមបច្ចេកវិទ្យា ។ ( សូមមើលវីដេអូអ្នកផ្សព្វផ្សាយសាសនាអំពីការបង្រៀនតាមបច្ចេកវិទ្យា ) ។*

តើអ្នកផ្សព្វផ្សាយសាសនាអាចបន្តទំនាក់ទំនងគេតាមផ្លូវឬទេ ?

*អ្នកផ្សព្វផ្សាយសាសនាគួរតែអនុវត្តតាមបង្គាប់ ច្បាប់ និងការណែនាំរបស់រដ្ឋាភិបាល ក៏ដូចជាការដឹកនាំមកពីគណៈប្រធានតំបន់ និងប្រធានបេសកកម្ម ។*

បើអ្នកផ្សព្វផ្សាយសាសនាម្នាក់ត្រូវបានសុំឲ្យផ្តល់ការប្រសិទ្ធពរមួយចំពោះនរណាម្នាក់ដែលមានរោគសញ្ញាកូរ៉ូណា តើអ្នកផ្សព្វផ្សាយសាសនាគួរតែផ្តល់ការប្រសិទ្ធពរឬទេ ?

*ទេ ។ អ្នកផ្សព្វផ្សាយសាសនាមិនគួរទៅជួបមនុស្សដែលបានធ្វើតេស្តវិជ្ជមាន បង្ហាញថាមានរោគសញ្ញា ឬបានប៉ះពាល់នឹងនរណាម្នាក់ដែលឆ្លងកូវីត ១៩ ។ ពួកគេអាចបម្រើដល់អ្នកនោះតាមបច្ចេកវិទ្យា ហើយអធិស្ឋានសម្រាប់ពួកគេ ។*

តើអ្នកផ្សព្វផ្សាយសាសនាគួរតែបន្តផ្តល់ការបម្រើ និងធ្វើការជាមួយនឹងកម្មវិធី JustServe ( គ្រាន់តែបម្រើ ) ឬទេ ?

*អ្នកផ្សព្វផ្សាយសាសនាគួរតែអនុវត្តតាមបង្គាប់ ច្បាប់ និងការណែនាំរបស់រដ្ឋាភិបាល ក៏ដូចជាការដឹកនាំមកពីគណៈប្រធានតំបន់ និងប្រធានបេសកកម្ម ។*

### កិច្ចការផ្សព្វផ្សាយសាសនារបស់សមាជិក

តើកិច្ចការផ្សព្វផ្សាយសាសនារបស់សមាជិកអាចបន្តឬទេ ?

> *បាទ នៅក្រោមការដឹកនាំរបស់ប្រធានស្តេក និងប៊ីស្សព ។ កិច្ចការផ្សព្វផ្សាយសាសនារបស់សមាជិកគឺស្ថិតក្រោមការដាក់កំហិតដដែលចំពោះការជួបផ្ទាល់ ដូចជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង រហូតដល់ស្ថានភាពអំណោយផល ។*

### ការប្រជុំអ្នកផ្សព្វផ្សាយសាសនា

ជំនួសឲ្យដំណើរទស្សនកិច្ចតាមបេសកកម្ម តើគណៈប្រធានតំបន់អាចចូលរួមក្រុមប្រឹក្សាថ្នាក់ដឹកនាំ និងការប្រជុំហ្សូនឬទេ ?

> *ការប្រមូលផ្តុំអ្នកផ្សព្វផ្សាយសាសនាជុំគ្នាដោយផ្ទាល់សម្រាប់ការប្រជុំហ្សូន គឺត្រូវបានផ្អាកជាបណ្តោះអាសន្ន ។ ការប្រជុំអាចធ្វើឡើងពីចម្ងាយដោយការប្រើប្រាស់បច្ចេកវិទ្យា តាមដែលចាំបាច់ ។*

## IV. កិច្ចការព្រះវិហារបរិសុទ្ធ

### ការសម្ភាសទទួលបណ្ណព្រះវិហារបរិសុទ្ធ និងការធ្វើឲ្យបណ្ណមានសុពលភាពវិញ

តើសមាជិកសាសនាចក្រគួរតែត្រូវបានលើកទឹកចិត្តឲ្យរក្សាបណ្ណចូលព្រះវិហារបរិសុទ្ធបច្ចុប្បន្នឬទេ ?

> *ប្រាកដណាស់ ។ បណ្ណព្រះវិហារបរិសុទ្ធបច្ចុប្បន្ន ទទួលស្គាល់ភាពសក្តិសមរបស់បុគ្គលម្នាក់ដើម្បីចូលព្រះវិហារបរិសុទ្ធ ទោះជាការថ្វាយបង្គំក្នុងព្រះវិហារបរិសុទ្ធពុំអាចធ្វើបាននៅពេលនេះក្តី ។*

តើការសម្ភាសទទួលប័ណ្ណចូលព្រះវិហារបរិសុទ្ធត្រូវតែបន្តធ្វើឡើងដោយផ្ទាល់ឬទេ ?

> *ទេ ។ សមាជិកនៃគណៈប៊ីស្សព និងគណៈប្រធានស្តេក អាចដឹកនាំការសម្ភាសទទួលបណ្ណចូលព្រះវិហារបរិសុទ្ធជាបណ្តោះអាសន្នដោយប្រើបច្ចេកវិទ្យាឃើញមុខគ្នា ។ សមាជិកគួរតែបន្តសម្ភាសដោយសមាជិកមួយរូបនៃគណៈប៊ីស្សព និងសមាជិកមួយរូបនៃគណៈប្រធានស្តេក ។*

តើប័ណ្ណចូលព្រះវិហារបរិសុទ្ធគួរតែចេញឲ្យទាំងគ្មានការចុះហត្ថលេខាឬទេ ?

*ប្រាកដណាស់ ។ សមាជិកគណៈប៊ីស្សពអាចធ្វើការសម្ភាសដោយប្រើបច្ចេកវិទ្យាដែលមាន ។ បន្ទាប់ពីការសម្ភាស ពួកគេអាចចុះហត្ថលេខា ថតរូបថតបណ្ណ ហើយផ្ញើរូបថតនោះទៅស្មៀនស្តេក ។ បន្ទាប់មកគាត់គួរតែប្រគល់ ឬផ្ញើរសំបុត្របណ្ណចូលព្រះវិហារបរិសុទ្ធដែលបានចុះហត្ថលេខានោះទៅឲ្យសមាជិក ។ សមាជិកគួរតែចុះហត្ថលេខាលើបណ្ណនោះពេលបានទទួល ។*

*បន្ទាប់ពីសមាជិកនៃគណៈប្រធានស្តេកសម្ភាសសមាជិក នោះគាត់ ឬស្មៀនស្តេក អាចធ្វើឲ្យបណ្ណនោះមានសុពលភាពទាំងគ្មានចុះហត្ថលេខាបាន ។ នៅពេលសាក្រាម៉ង់រួដ និងការប្រជុំដទៃទៀតត្រឡប់មកដូចដើម នោះសមាជិកគួរតែមានបណ្ណរបស់ពួកគេចុះហត្ថលេខាដោយសមាជិកនៃគណៈប្រធានស្តេក បើពុំទាន់បានចុះហត្ថលេខាទេនោះ ។*

## V. បន្ថែមសំណួរផ្សេងទៀត

តើយើងគួរតែបន្តចូលរួមនៅក្នុងការបរិច្ចាគឈាមឬទេ ?

*បាទ ការបរិច្ចាគឈាមនឹងបន្តមាន ប៉ុន្តែត្រូវតែធ្វើតាម ការដាក់បង្គាប់, ច្បាប់របស់រដ្ឋាភិបាល និងការណែនាំដែលបានបង្កើតឡើងដោយទីតាំងនីមួយៗ និងប្រត្រកូលនៃស្ថាប័នបរិច្ចាគឈាម (កាកបាទក្រហម ឬផ្សេងទៀត )។ សាលាប្រជុំមិនគួរប្រើសម្រាប់គោលបំណងទាំងនេះឡើយ ទាល់តែមានការជូនដំណឹងបន្ថែម ។ កន្លែងចតឡានក្នុងសាលាប្រជុំ អាចត្រូវបានប្រើដោយអង្គការកាកបាទក្រហម និងស្ថាប័នដទៃទៀត ដោយប្រើកន្លែងចល័ត បើធ្វើតាម ការដាក់បង្គាប់, ច្បាប់ និងការណែនាំរបស់រដ្ឋាភិបាល ។*

តើថ្នាក់ដឹកនាំគួរតែជូនដំណឹងទៅកាន់សមាជិកទាំងឡាយដែលអាចនឹងទំនាក់ទំនងនឹងសមាជិកសាសនាចក្រដទៃទៀត ដែលប៉ះពាល់ ឬឆ្លងកូវីត ១៩ ឬទេ ?

*ជាទូទៅ បាទ រួមទាំងផ្តល់ដំបូន្មានដល់ថ្នាក់ដឹកនាំ និងបងប្អូនប្រុសស្រីដែលផ្តល់ការងារបម្រើដែលមានកាតព្វកិច្ច ដែលនឹងនាំឲ្យពួកគេទាក់ទងនឹងសមាជិកដែលឆ្លង ។ ថ្នាក់ដឹកនាំ និងបងប្អូនប្រុសស្រីដែលផ្តល់ការងារបម្រើទាំងនេះ គួរតែផ្តល់ដំបូន្មានឲ្យបន្តផ្តល់ការងារបម្រើ ប៉ុន្តែតាមបច្ចេកវិទ្យា និងពីចម្ងាយ ហើយធ្វើតាមការណែនាំនៅក្នុង « វង្វាស់ការបង្ការសម្រាប់*

*សមាជិក »។ សមាជិក  គួរតែធ្វើតាមច្បាប់ រួមទាំងការដាក់បង្គាប់ច្បាប់ និងការណែនាំរបស់រដ្ឋាភិបាល ។*

***សំណួរបន្ថែមគួរតែសួរទៅកាន់គណៈប្រធានតំបន់ ដែល អាចផ្តល់ការណែនាំដែលចាំបាច់ ។***